ACCESS 2
Sustainable quality services for all

Australian Aid



កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2) គឺជាការបន្តនៃការវិនិយោគទ្វេភាគីរបស់ប្រទេសអូស្ត្រាលីលើសមភាពយេនឌ័រ ពិការភាព ការស្តារលទ្ធភាពពលកម្ម និងបរិយាបន្នសង្គមនៅកម្ពុជា។ ក្នុងរយៈពេល៥ឆ្នាំ (២០២៣ - ២០២៨) រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ថវិកាចំនួន៣០លានដុល្លារអូស្ត្រាលី ផ្តោតលើការបង្កើនលទ្ធភាពទទួលបានសេវាប្រកបដោយគុណភាព និងបរិយាបន្នសម្រាប់ជនមានពិការភាព និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។

ACCESS 2 នឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការតំណាងជនមានពិការភាព (OPDs) ក្រុមគាំទ្រស្ត្រី និងអង្គការតំណាងជនជាតិដើមភាគតិច ដើម្បីអនុវត្តន៍នូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព ទទួលបានសេវាដែលពួកគេត្រូវការកាន់តែប្រសើរ។

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ**

**បរិយាបន្នពិការភាព**

**ការស្តារលទ្ធភាពពលកម្ម**

**ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

គោលដៅទូទៅនៃកម្មវិធី **ACCESS 2** គឺ៖ ជនមានពិការភាព និងជនរងគ្រោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ទទួលបានអត្ថប្រយោជន៍ពីការទទួលបានសេវាប្រកបដោយគុណភាព និងសេវាប្រកបដោយការសម្របសម្រួល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

**មានលទ្ធផលវិនិយោគចុងបញ្ចប់កម្មវិធី (EOIOs) ចំនួន២ដូចខាងក្រោម ដែលរួមចំណែកដល់ការសម្រេចបានគោលដៅទូទៅនៃកម្មវិធី៖**

## EOIO 1:

ត្រឹមឆ្នាំ២០២៨ អ្នកផ្តល់សេវាដែលបានជ្រើសរើសនឹងផ្តល់សេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសេវាទាក់ទងនឹងពិការភាពដែលមានគុណភាពខ្ពស់ជាងមុនដល់អ្នកទទួលផលកាន់តែច្រើននៅក្នុងខេត្តគោលដៅ។

## EOIO 2:

ត្រឹមឆ្នាំ២០២៨ គោលនយោបាយ និងដំណើរការរៀបចំផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានការឆ្លើយតបទៅនឹងអាទិភាពរបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព។

ACCESS 2
Sustainable quality services for all

Australian Aid

# វិសាលភាពភូមិសាស្រ្ត

## ACCESS 2 នឹងផ្តោតលើខេត្តគោលដៅចំនួន៤ ព្រមទាំងរាជធានីភ្នំពេញ។




## ក្នុងចង្វាក់លទ្ធផលកម្មវិធី ACCESS 2 ការកំណត់គុណភាពនៃសេវា មានដូចជា៖

- ជាសុករវត្ត និងបរិយាបន្ន
- ឆ្លើយតបទាន់ពេលវេលា និងការសម្របខ្លួន
- អាចរកបាន និងសង្គតិភាព
- សម្របសម្រួល
- ផ្តល់ភស្តុតាង
- និរន្តរភាព
- សុវត្ថិភាព




សូមចូលទៅកាន់គេហទំព័រ
អាសយដ្ឋាន៖ អគារអានីណា ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទការិយាល័យ៖ (៨៥៥) ១២ ៨៧៦ ៥៤៩
សារអេឡិចត្រូនិក៖ info@access2cambodia.org
គេហទំព័រ៖ www.access2cambodia.org